ព្រះរាជទម្លាប់មក ដោយហេតុតែព្រះអង្គទ្រង់ពិចារណាឃើញថា ព្រះអង្គម្ចាស់ទាំងពីរប្រកបដោយបញ្ញាឈ្លាសវៃ និងសេចក្ដីអង់អាចណាស់ ព្រះអង្គក៏ទ្រង់មានព្រះទ័យអន្ទះអន្ទែងចង់សន្ទនា ដោយសេរីជាមួយព្រះអង្គម្ចាស់ ទើបព្រះអង្គប្រញាប់យាងត្រឡប់ទៅព្រះបរមរាជវាំងវិញដូច្នេះ ។ នៅពេលធ្វើដំណើរយាងចេញទៅព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យអនុញ្ញាតឱ្យព្រះអង្គម្ចាស់ទាំងពីរបរសេះទន្ទឹមសង្ខាងព្រះអង្គ គឺជាកិត្តិយសដែលបណ្ដាលឱ្យកើតសេចក្ដីច្រណែន, មិនត្រឹមតែពីពួកមន្ត្រីធំៗក្នុងព្រះរាជវាំងទេ, សូម្បីតែលោកនាយករដ្ឋមន្ត្រីក៏មានសេចក្ដីអន់ចិត្តដែរ កាលបើឃើញព្រះអង្គម្ចាស់ទាំងពីរបានទទួលកិត្តិយសយ៉ាងមុខលោកដូច្នោះ ។

កាលបើព្រះបាទស៊ុលតង់យាងចូលទៅដល់ក្នុងព្រះរាជធានីហើយ, ប្រជាពលរដ្ឋដែលស្ថិតនៅសង្ខាងវិថី បានខំសម្លឹងមើលតែព្រះអង្គម្ចាស់បាម៉ាននិងព្រះអង្គម្ចាស់ប៉ែរិស ដោយចង់ដឹងថា តើព្រះអង្គម្ចាស់ទាំងពីរនោះជានរណា ជាជនបរទេស ឬក៏ជាជនក្នុងនគរនោះទេ ។ អ្នកខ្លះក៏បានពោលថា : “ទោះជាយ៉ាងណាក៏ដោយ, សូមឱ្យព្រះអាទិទេពមេត្តាដាក់ទានឱ្យព្រះបាទស៊ុលតង់ មានព្រះរាជបុត្រពីរព្រះអង្គ ហើយមានព្រះរូបល្អឥតខ្ចោះប្រកបដោយទឹកព្រះភក្ត្ររីករាយដូច្នេះកុំខាន បើសិនជាព្រះនាងស៊ុលតានបានប្រសូតបុត្រមកដូចប្រក្រតីធម្មតា, នោះព្រះរាជបុត្រព្រះអង្គប្រហែលជាមានព្រះជន្មធំប៉ុនៗនេះទៅហើយ” ។



វត្ថុទីមួយដែលព្រះបាទស៊ុលតង់ទ្រង់បានធ្វើដល់ព្រះអង្គម្ចាស់ នៅពេលយាងទៅដល់ព្រះបរមរាជវាំង គឺព្រះអង្គទ្រង់បាននាំព្រះអង្គម្ចាស់ទតមើលបន្ទប់ទាំងឡាយក្នុងប្រាសាទ ហើយព្រះអង្គម្ចាស់ក៏ទ្រង់ស្ងើចសរសើរលម្អគ្រឿងសង្ហារិម, ភាពឆើតឆាយ, ក្បាច់រចនាផ្សេងៗនិងសទិសសណ្ឋាន ។ នៅទីបំផុតគេក៏រៀបចំអាហារភោជនយ៉ាងល្អបំផុតថ្វាយព្រះអង្គម្ចាស់សោយ, ព្រះបាទស៊ុលតង់ក៏អញ្ជើញព្រះអង្គម្ចាស់គង់តុសោយក្រយាព្រះស្ងោយជាមួយព្រះអង្គ ។ ព្រះអង្គម្ចាស់ទាំងពីរបម្រុងប្រកែកដែរ ប៉ុន្តែព្រះអង្គម្ចាស់ទ្រង់យល់ព្រមតាមវិញ កាលបើព្រះបាទស៊ុលតង់មានព្រះបន្ទូលថា គឺជាឆន្ទៈព្រះអង្គ ។

ព្រះបាទស៊ុលតង់ជាក្សត្រទ្រង់ប្រកបដោយបញ្ញាខ្ពង់ខ្ពស់ ហើយទ្រង់មានការយល់យ៉ាងជ្រៅជ្រះខាងវិទ្យាសាស្ត្រ ពិសេសគឺខាងប្រវត្តិសាស្ត្រ ។ ដូច្នេះ ព្រះអង្គបានទ្រង់ចិន្តាទុកជាមុនថា នឹងផ្ដើមរករឿងមានព្រះបន្ទូលមុនព្រះអង្គម្ចាស់, មិនទុកឱ្យព្រះអង្គម្ចាស់មានព្រះបន្ទូលមុនព្រះអង្គបានឡើយ ។ ដោយហេតុនេះ ព្រះអង្គក៏ចាប់មានព្រះបន្ទូលមុន រួចជាបន្តបន្ទាប់មកការសន្ទនាក៏ចេះតែមានហូរហែក្នុងពេលសោយក្រយាព្រះស្ងោយ ។ ប៉ុន្តែនៅគ្រប់រឿងនៃការសន្ទនានោះ ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលប្រកបដោយការចេះដឹង, ការឈ្លាសវៃ, ការវិនិច្ឆ័យនិងការស្គាល់ខុសស្គាល់ត្រូវជាដរាប ដែលជាហេតុនាំឱ្យព្រះបាទស៊ុលតង់ទ្រង់ស្ងើចសរសើរជាទីបំផុត ។ ទើបព្រះអង្គទ្រង់

ព្រះចិន្តាក្នុងព្រះទ័យថា : "បើសិនជាកុមារទាំងពីរនេះ ដែលប្រកប ដោយបញ្ញាយ៉ាងនេះស្រាប់ហើយ បានទៅជាបុត្ររបស់ខ្ញុំ ហើយទោះ បីខ្ញុំនឹងអប់រំវាដោយខ្លួនខ្ញុំផ្ទាល់ទៀតក៏ដោយ, ក៏យុវជននេះគ្មានចេះ អ្វីឱ្យលើសពីនេះទៅទៀតបានដែរ" ។ បន្ទាប់ពីការសន្ទនាយ៉ាងវែង ជាមួយព្រះអង្គម្ចាស់នៅនឹងតុក្រយាព្រះស្ងោយមក, ព្រះអង្គក៏ទ្រង់ អញ្ជើញព្រះអង្គម្ចាស់ទៅសន្ទនានៅក្នុងការិយាល័យព្រះអង្គទៀត ។ នៅទីបំផុត ព្រះអង្គក៏មានព្រះបន្ទូលថា : "ខ្ញុំពុំបាននឹកស្មានថា នៅទី ដំបន់ជនបទមានអភិជនក្មេងៗ ដូច្នោះដែលជាកូនចៅខ្ញុំ, មានការអប់រំ យ៉ាងខ្ពង់ខ្ពស់, មានចំណេះបញ្ញាប៉ិនប្រសប់ជ្រៅជ្រះដូច្នេះសោះ ។ តាំងពីខ្ញុំកើតមក, ខ្ញុំពុំដែលបានសន្ទនាអ្វីឱ្យបានសប្បាយដូចជាបាន សន្ទនាជាមួយនឹងឯងនេះទេ។ ប៉ុន្តែប៉ុណ្ណេះគ្រប់គ្រាន់ល្មមហើយ ព្រោះ ដល់ពេលអ្នកត្រូវឈប់សម្រាកលំហែកាយមើលការរាំច្រៀងផ្សេងៗ នៅក្នុងព្រះបរមរាជវាំងខ្ញុំនេះ ។ ប៉ុន្តែដោយគ្មានល្បែងអ្វី ដែលអាច ឱ្យឯងបាត់អផ្សុកបានក្រៅពីភ្លេងនោះ សូមឯងអញ្ជើញទៅស្ដាប់តូរ្យ-តន្ត្រីដែលគេកំពុងលេងនោះទៅ" ។

កាលបើព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលចប់ភ្លាម អ្នក ភ្លេងដែលបានទទួលបង្គាប់ក៏ចូលមកសម្ដែងវិជ្ជាខ្លួនយ៉ាងប៉ិនប្រសប់ ។ ពួកអ្នកក្រមាច់យ៉ាងល្បីៗឈ្មោះក៏ឡើងកំប្លែងបន្ទរនឹងភ្លេង, នាងករ នាងការីទាំងឡាយបានឡើងរាំបញ្ចប់ការសប្បាយយ៉ាងល្អមើលណាស់



ព្រះអង្គម្ចាស់ទាំងពីរ កាលបើយល់ថា ពេលកាន់តែល្ងាចជិត យប់ហើយ ក៏ឱនលុតជង្គង់ថ្វាយបង្គំសុំលាព្រះបាទស៊ុលតង់ ក្រោយ ពីបានសម្ដែងអំណរគុណព្រះអង្គចំពោះព្រះទ័យសប្បុរសនឹងកិត្តិយស ដែលព្រះអង្គទ្រង់បានធ្វើមកលើខ្លួន ។ ព្រះបាទស៊ុលតង់ក៏ទ្រង់យល់ ព្រម ហើយមានព្រះបន្ទូលថា: "យើងអនុញ្ញាតឱ្យឯងទៅហើយៗសូម ឯងនឹកថា យើងបាននាំអ្នកមកកាន់ព្រះរាជវាំងយើងដោយផ្ទាល់ខ្លួន យើងដូច្នេះ ដើម្បីឱ្យឯងស្គាល់ផ្លូវប្រយោជន៍ដល់ថ្ងៃក្រោយ ឯងមក លេងផ្ទាល់ខ្លួនឯងតែម្ដង ។ ឯងនឹងត្រូវបានគេទទួលដោយរីករាយ ហើយដរាបណាឯងបានមកលេងនឹងយើងញឹកញយ ដរាបនោះឯងក៏ បានធ្វើឱ្យយើងសប្បាយច្រើនដែរ" ។

មុននឹងថ្វាយបង្គំលាព្រះរាជាចេញពីព្រះរាជវាំងទៅ ព្រះអង្គ ម្ចាស់បាម៉ានទ្រង់មានព្រះបន្ទូលថា : "បពិត្រព្រះនរបតីជាម្ចាស់ជីវិត លើត្បូង, ទូលព្រះបង្គំយើងខ្ញុំសូមអង្វរព្រះករុណាថ្លៃវិសេស សូមព្រះ អង្គទ្រង់មេត្តាអនុគ្រោះដល់ទូលព្រះបង្គំនឹងដល់ប្អូនស្រីទូលព្រះបង្គំ ផង គឺសូមព្រះអង្គទ្រង់យាងកាត់តាមផ្លូវផ្ទះទូលព្រះបង្គំ ហើយយាង ចូលសម្រាកព្រះកាយក្នុងគេហស្ថានទូលព្រះបង្គំ តាមពេលដ៏គួរ, នៅ ពេលណាមួយដែលព្រះអង្គទ្រង់បានយាងទៅកំសាន្តបរបាញ់សត្វនៅទី ជិតៗនោះ ។ ពិតមែនហើយតែកន្លែងនោះមិនសមនឹងព្រះអង្គយាង ចូលទេ ប៉ុន្តែនៅពេលខ្លះ, ព្រះរាជាក៏ទ្រង់សព្វព្រះរាជហឫទ័យនឹង

ចូលសម្រាកព្រះកាយពលនៅក្នុងផ្ទះខ្ទមដែរ" ។ ព្រះបាទស៊ុលតង់ក៏ទ្រង់មានព្រះបន្ទូលតបថា : "គេហស្ថានរបស់អធិជនទាំងឡាយដូចជារូបឯងនេះ ជាគេហស្ថានល្អហើយសមនឹងកិត្តិយសឯងណាស់ ។ យើងនឹងមានសេចក្ដីសោមនស្សនឹងទៅមើលណាស់ សោមនស្សដោយបានឃើញឯងនឹងប្អូនស្រីឯង ដែលយើងមានសេចក្ដីរីករាយជាមុនៗ ដែលយើងបានទៅឃើញនាងធ្វើជាម្ចាស់ផ្ទះនោះ ព្រោះយើងបានស្គាល់គុណសម្បត្តិរបស់នាងតាមដំណើរ ដែលឯងបាននិយាយប្រាប់យើងខ្លះមកហើយ ។ ដូច្នេះយើងនឹងទៅលេងផ្ទះឯងនៅពេលឆាប់ៗ មិនហួសពីថ្ងៃខានស្អែកនេះឡើយ ។ នៅពេលព្រលឹមធំ, យើងនឹងដល់កន្លែងដែលយើងបានជួបនឹងឯងពីថ្ងៃមុន សូមឯងនៅចាំយើងត្រង់កន្លែងនោះពុំខាន ដើម្បីនាំផ្លូវយើងទៅកាន់ផ្ទះឯង" ។

នៅថ្ងៃដដែលនោះ ព្រះអង្គម្ចាស់បាម៉ាននិងប៉ែរិសក៏បានយាងត្រឡប់ទៅដល់គេហស្ថានវិញ ។ លុះយាងទៅដល់ ព្រះអង្គម្ចាស់ក៏មានព្រះបន្ទូលប្រាប់ព្រះអង្គម្ចាស់ក្សត្រីអំពីបដិសណ្ឋារកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ដែលទ្រង់បានទទួលពីព្រះបាទស៊ុលតង់ ហើយព្រះអង្គម្ចាស់បានបញ្ជាក់ថា ព្រះអង្គទ្រង់យល់ប្រមសម្រេចថានឹងយាងមកលេងផ្ទះយើងនៅថ្ងៃខានស្អែកនេះ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា: "បើសិនជាការនេះដូច្នេះមែន, ត្រូវយើងគិតរៀបចំក្រយាព្រះស្ងោយយ៉ាងណាឱ្យសមនឹង



ឋានៈព្រះអង្គ ។ ប៉ុន្តែជាការប្រពៃត្រូវយើងពិគ្រោះយោបល់បក្សាចេះនិយាយសិន ។

បក្សាប្រហែលជានឹងប្រាប់ម្ហូបឆ្ងាញ់ៗឱ្យយើងធ្វើ ឱ្យបានសមនឹងពោធិបារមីព្រះមហាក្សត្រា ។ ព្រះអង្គម្ចាស់ព្រះរៀមទាំងពីរក៏យល់ព្រម រួចនៅពេលព្រះអង្គម្ចាស់ព្រះរៀមយាងថយចេញទៅ, ព្រះនាងក៏នៅពិគ្រោះនឹងបក្សាតែមួយព្រះអង្គឯង ។ ព្រះនាងមានព្រះសវនីយ៍ថា : "បក្សាព្រះបាទស៊ុលតង់ទ្រង់សព្វព្រះរាជហឫទ័យយាងមកលេងផ្ទះយើងនេះ ហើយយើងត្រូវតែរៀបចំក្រយាព្រះស្ងោយទទួលព្រះអង្គ ។ ដូច្នេះសូមឯងនិយាយប្រាប់ខ្ញុំមក, តើឱ្យខ្ញុំរៀបចំធ្វើម្ហូបអាហារយ៉ាងម៉េច ដើម្បីឱ្យបានសព្វព្រះទ័យព្រះអង្គ" ។

បក្សាក៏ឆ្លើយថា: "អ្នកស្រីជាចៅហ្វាយដ៏ប្រសើររបស់ខ្ញុំ, អ្នកស្រីមានចុងភៅយ៉ាងចំណានៗជាច្រើន សូមឱ្យចុងភៅទាំងនេះ ធ្វើម្ហូបណាដែលខ្លួនយល់ថាប្រសើរជាងគេទាំងអស់ ប៉ុន្តែសំខាន់បំផុត, សុំឱ្យចុងភៅធ្វើម្ហូបត្រសក់ញាត់ទិមគជ់មួយចាន ។ ម្ហូបត្រសក់នេះ សូមអ្នកស្រីលើកយកទៅថ្វាយព្រះរាជាសោយមុនគេបង្អស់ ព្រោះជារបស់ប្រសើរជាងគេ" ។

- ត្រសក់ញាត់ទិមគជ់ ! ព្រះអង្គម្ចាស់ក្សត្រីទ្រង់ស្រែកទ្រហោដោយសេចក្ដីងឿងឆ្ងល់ ។ បក្សា, អ្នកឥតនឹកឃើញទេឬ គឺជាម្ហូបដែលគេពុំដែលឮសោះ ។ ព្រះបាទស៊ុលតង់ទ្រង់នឹងសរសើរពុំខាន





ថាជារបស់ឆើតឆាយរុងរឿងឧត្តុង្គឧត្តម ប៉ុន្តែត្រូវដឹងថា ព្រះអង្គទ្រង់គង់នៅនឹងតុ ដើម្បីសោយក្រយា មិនមែនព្រះអង្គទ្រង់សរសើរគជ់ទេ។ ក្រៅពីនេះ, កាលបើខ្ញុំយកគជ់ខ្ញុំមកប្រើការដូច្នេះមែន ក៏ខ្ញុំគ្មានគ្រប់គ្រាន់សម្រាប់ធ្វើទឹមញាត់ត្រសក់នេះដែរ ។

- អ្នកស្រី, បក្សាឆ្លើយ, សូមអ្នកស្រីធ្វើតែតាមខ្ញុំជម្រាបទៅ ហើយសូមកុំព្រួយក្រែងមានកើតរឿងហេតុអ្វីឱ្យសោះ មានតែអំពើល្អទេដែលអាចកើតមានបាន ។ ចំណែកឯគជ់វិញ, ស្អែកនេះនៅពេលពីព្រលឹមបំផុត, សូមអ្នកស្រីអញ្ជើញទៅកាន់គល់ឈើក្នុងសួនអ្នកស្រីដែលដុះនៅដើមគេបង្អស់ ហើយនៅខាងស្ដាំដៃ, រួចសុំឱ្យគេជីកត្រង់គល់ឈើនោះ អ្នកស្រីនឹងបានឃើញគជ់លើសចំនួនដែលអ្នកស្រីត្រូវការទៅទៀត ។

ចាប់តាំងពីល្ងាចនៃថ្ងៃនោះម្ល៉េះ, ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដបានទ្រង់ប្រាប់អ្នកថែរក្សាសួន ឱ្យប្រុងប្រៀបខ្លួនឱ្យស្រេច។ លុះស្អែកឡើង នៅពេលពីព្រលឹម ព្រះនាងក៏នាំអ្នកថែរក្សាសួនទៅកាន់ដើមឈើ ដែលបក្សាបានប្រាប់ រួចក៏ទ្រង់បង្គាប់ឱ្យអ្នកថែរក្សាសួនជីកត្រង់គល់ឈើនោះ ។ កាលបើអ្នកថែសួនច្បារជីកបានជ្រៅបន្តិចទៅ គាត់ក៏ហាក់ដូចជាជីកលែងមុតទៅទៀត, រួចគាត់ក៏សម្លឹងទៅឃើញប្រអប់តូចមួយ ធ្វើអំពីមាសមានរាងបួនជ្រុងស្មើ មួយជ្រុង១ប្រវែងមួយជំហាន (០.៣២៤៨ម) ។ គាត់ក៏ចង្អុលបង្ហាញព្រះអង្គម្ចាស់ក្សត្រី១ក៏

មានសវនីយ៍ថា : “គឺអាស្រ័យហេតុនេះហើយបានជាខ្ញុំនាំឯងមក. ចូរឯងជីកតទៅទៀត ហើយប្រយ័ត្នកុំឱ្យប៉ះនឹងផ្លែចប” ។

នៅទីបំផុត, អ្នកថែសួនច្បារក៏ជីកយកបានប្រអប់នោះថ្វាយទៅព្រះអង្គម្ចាស់ក្សត្រី ។ ដោយហេតុថា ប្រអប់នោះបិទភ្ជិតដោយស្រយូវយ៉ាងតូចស្អាត. ព្រះអង្គម្ចាស់ក្សត្រីក៏បើកបានហើយទតឃើញសុទ្ធតែគជ់. មានទំហំដ៏តូច ប៉ុន្តែស្អាតហើយសមនឹងយកមកប្រើតាមសេចក្តីត្រូវការណាស់ ។ បន្ទាប់ពីបានបិទប្រអប់នោះទៅវិញ. ព្រះនាងក៏កាន់ប្រអប់នោះយាងត្រឡប់មកលំនៅ ប្រកបដោយសេចក្តីសោមនស្សជាពន់ប្រមាណ ទុកអ្នកថែសួនឱ្យនៅលុបដីត្រង់កន្លែងនោះឱ្យរាបស្មើដូចពីដើមវិញ ។

ព្រះអង្គម្ចាស់បាម៉ាននិងប៉ែវិស ដោយទ្រង់បានទតឃើញព្រះអង្គម្ចាស់ក្សត្រីជាព្រះអនុជ នៅក្នុងសួនច្បារទាំងព្រលឹមខុសពីទម្លាប់ធម្មតាមកដូច្នេះ ក៏យាងចុះពីដំណាក់ព្រះអង្គរៀង១ខ្លួនតម្រង់ឆ្ពោះទៅរកព្រះនាង នៅពេលដែលព្រះអង្គទ្រង់ស្លៀកពាក់តែងព្រះកាយរួច ។ ព្រះអង្គម្ចាស់ទាំងពីរ ក៏បានយាងទៅជួបព្រះនាងនៅត្រង់ពាក់កណ្តាលសួនច្បារ ហើយដោយព្រះអង្គម្ចាស់ទតពីចម្ងាយ ឃើញព្រះនាងមានកាន់របស់អ្វីនៅនឹងព្រះហស្ត. លុះយាងទៅដល់ជិតទៅ. ព្រះអង្គម្ចាស់ក៏បានស្គាល់ថាជាប្រអប់មាសតូចមួយ. ទើបទ្រង់កើតសេចក្តីងឿងឆ្ងល់ជាពន់ប្រមាណ ។ ព្រះអង្គម្ចាស់បាម៉ានក៏ត្រាស់សួរទៅព្រះនាងភ្លាមថា : “ម្ចាស់អូន. កាលម្ចាស់អូនយាងទៅជាមួយអ្នកថែសួន. ម្ចាស់បងឥតឃើញមានកាន់អ្វីសោះ. ឥឡូវលុះម្ចាស់អូនយាងត្រឡប់មកវិញ ក៏ស្រាប់តែឃើញកាន់ប្រអប់មាសនេះ។ តើរបស់នេះជាកំណប់ដែលអ្នកថែសួនច្បារបានឃើញ ហើយមកប្រាប់ម្ចាស់អូនឬ?”



- ម្ចាស់ព្រះរៀម. ព្រះអង្គម្ចាស់ក្សត្រីមានសវនីយ៍ គឺជាការយល់ផ្ទុយទាំងអស់ គឺខ្លួនម្ចាស់អូននេះទេ ដែលបាននាំអ្នកថែសួនទៅប្រាប់កន្លែងប្រអប់នេះ. ហើយអ្នកថែសួនច្បារក៏បានជីកយកប្រអប់នេះបានឱ្យម្ចាស់អូន។ ម្ចាស់ព្រះរៀមរឹតតែត្រេអរនឹងសេចក្តីដ៏ប្រសើរនេះណាស់ កាលបើម្ចាស់ព្រះរៀមបានទតឃើញរបស់នៅក្នុងប្រអប់នេះទៀត ។

ព្រះអង្គម្ចាស់ក្សត្រីក៏បើកប្រអប់នោះឡើង. ព្រះអង្គម្ចាស់ក៏បានឃើញសុទ្ធតែគជ់ មានទំហំមិនជាសម្បើមប៉ុន្មានទេ ប៉ុន្តែ ជារបស់មានតម្លៃក្រៃលែង បើប្រៀបទៅនឹងភាពល្អឥតខ្ចោះនឹងចំនួននៃគជ់នោះ ។ ដូច្នេះ ព្រះអង្គម្ចាស់ក៏ទ្រង់ត្រាស់សួរទៅព្រះនាងថា តើដោយដំណើរយ៉ាងណាបានជាព្រះនាងបានដឹងកន្លែងកំណប់នេះ ។ ព្រះនាងក៏ទ្រង់ឆ្លើយថា : “ម្ចាស់ព្រះរៀម. បើសិនជាម្ចាស់ព្រះរៀមគ្មានការប្រញាប់ពេកណាស់ទេ. សូមម្ចាស់ព្រះរៀមមកជាមួយម្ចាស់អូន១នឹងរៀបរាប់ទូល” ។ ព្រះអង្គម្ចាស់ប៉ែវិសក៏មានព្រះបន្ទូលតបថា : “គ្មានការប្រញាប់ឯណាដែលអាចធ្វើឱ្យយើងខានដឹងរឿងនេះទេ ។ យើងគ្មានការអ្វីទៀតក្រៅពីមកជួបនឹងម្ចាស់អូនទេ” ។

នៅពេលនោះ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដទ្រង់យាងត្រឡប់ទៅលំនៅបណ្ដើរ, មានសវនីយ៍ទូលម្ចាស់ព្រះវរៀមបណ្ដើរអំពីរឿងដែលព្រះនាងបានពិគ្រោះជាមួយបក្សា។ បន្ទាប់ពីម្ចាស់ព្រះវរៀមបានយល់ព្រមផង, ដើម្បីរៀបធ្វើម្ហូបថ្វាយព្រះរាជា, អំពីការដែលព្រះនាងបានឆ្លើយជំទាស់នឹងបក្សា អំពីរឿងធ្វើម្ហូបត្រសក់ញាត់ទឹមគុជហើយនិងអំពីមធ្យោបាយដែលបក្សាបានប្រាប់កន្លែងលាក់គជ់ ដែលម្ចាស់អូនទើបនឹងយកបានមកនេះ ដើម្បីប្រើការធ្វើម្ហូបតាមសម្ដីបក្សាព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីបានទ្រង់ប្ដូរយោបល់គ្នាជាច្រើនដើម្បីឱ្យបានយល់បំណងបក្សា, ដែលចង់ឱ្យគេធ្វើម្ហូបយ៉ាងនេះ ថ្វាយព្រះបាទស៊ុលតង់ ព្រមទាំងជួយប្រាប់មធ្យោបាយ ដើម្បីធ្វើម្ហូបនោះឱ្យទាល់តែកើតផង ។ ប៉ុន្តែនៅទីបំផុត, ព្រះអង្គម្ចាស់ទាំងឡាយពុំអាចយល់ដូចម្ដេចបានឡើយ ប៉ុន្តែទ្រង់ក៏បានមូលមតិថា ត្រូវតែធ្វើតាមដំបូន្មានបក្សាកុំបីខ្វះកន្លែងណាឱ្យសោះឡើយ ។

លុះចូលទៅដល់ក្នុងផ្ទះ ព្រះនាងក៏ទ្រង់មានព្រះរាជឱង្ការឱ្យគេទៅហៅនាយចុងភៅមកជួបនឹងព្រះនាងនៅក្នុងបន្ទប់ព្រះនាង ។ រួចក្រោយពីព្រះនាងបានបង្គាប់ដល់នាយចុងភៅឱ្យប្រុងប្រៀបរៀបចំធ្វើក្រយាព្រះស្ងោយដើម្បីជប់លៀងព្រះបាទស៊ុលតង់ ព្រះនាងទ្រង់មានព្រះសវនីយ៍បន្ថែមដូច្នេះថា : "ក្រៅពីការដែលខ្ញុំទើបនឹងបាននិយាយប្រាប់អ្នកនេះ, ចូរអ្នកធ្វើម្ហូបមួយមុខតាមបង្គាប់ខ្ញុំ ដើម្បីថ្វាយ



ព្រះរាជាសោយ ហើយអ្នកមិនត្រូវបណ្ដោយអ្នកណាឱ្យធ្វើក្រៅពីដៃអ្នកផ្ទាល់ឡើយ ។ ម្ហូបនោះគឺត្រសក់ញាត់ទឹម, ប៉ុន្តែទឹមនោះត្រូវយកគជ់នេះទៅធ្វើ" ។ នៅពេលនោះ, ព្រះនាងក៏បើកប្រអប់ឡើងបង្ហាញគជ់ឱ្យនាយចុងភៅមើល ។

នាយចុងភៅ ដែលពុំធ្លាប់បានឮគេពោលពីទឹមដូច្នេះសោះ, ក៏ដើរថយក្រោយពីរជំហាន, ធ្វើមុខស្មឿកសម្ដែងនូវការងឿងឆ្ងល់ ។ ព្រះអង្គម្ចាស់ក្សត្រីយល់នូវអាកប្បកិរិយាដូច្នេះ ក៏មានព្រះសវនីយ៍ថា: "ខ្ញុំដឹងច្បាស់ណាស់ថា អ្នកមុខជាទុកខ្ញុំជាមនុស្សវិកលចរិកហើយ, បានជាបង្គាប់អ្នកឱ្យធ្វើម្ហូប ដែលអ្នកពុំដែលឮគេនិយាយម្ដងណាសោះហើយដែលគេអាចពោលយ៉ាងប្រាកដថា គ្មាននរណាគេដែលធ្វើម្ហូបដូច្នេះទេ ។ ការនេះពិតដូច្នេះមែន ខ្ញុំក៏ដឹងដូចជាអ្នកដែរ ប៉ុន្តែខ្ញុំឥតឆ្កួតទេ គឺខ្ញុំប្រកបដោយសុភវិនិច្ឆ័យបរិបូណ៌ ដែលខ្ញុំបង្គាប់ឱ្យអ្នកធ្វើនេះ ។ ហេតុនេះ ចូរអ្នកត្រឡប់ទៅវិញ ប្រឹងធ្វើឡើងតាមការប៉ិនប្រសប់របស់អ្នក។ ដូច្នេះចូរអ្នកយកប្រអប់គជ់នេះទៅ រួចយកប្រអប់និងគជ់នៅសល់មកឱ្យខ្ញុំវិញ បើសិនជាគជ់នេះប្រើការមិនអស់" ។ នាងចុងភៅគ្មានអ្វីឆ្លើយឆ្លងនឹងព្រះនាងទៀត ក៏កណ្ដៀតយកប្រអប់នោះទៅ ។ នៅថ្ងៃដដែលនោះ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដបានទ្រង់បង្គាប់ឱ្យគេរៀបចំបោសសម្អាតជូតលាងរបស់អ្វីៗឱ្យបានស្អាត ហើយឱ្យមានរបៀបរៀបរយទាំងអស់, ទាំងខាងក្នុងផ្ទះក៏ដូចជានៅក្នុងសួន

ដើម្បីទទួលព្រះបាទស៊ុលតង់ឱ្យបានថ្លៃថ្នូរ. សមរម្យនឹងព្រះរាជឋានៈព្រះអង្គ ។

លុះស្អែកឡើង នៅពេលដែលព្រះបាទស៊ុលតង់ប្រទេសពែរ្ស៍យាងមកដល់កន្លែងបរបាញ់សត្វ. ព្រះអង្គម្ចាស់ព្រះវៀមទាំងពីរបានយាងទៅគង់រង់ចាំ ទទួលព្រះអង្គនៅត្រង់កន្លែងនោះជាមុនស្រេចទៅហើយ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ចាប់បរបាញ់សត្វ រហូតដល់ពេលទៀបថ្ងៃត្រង់ទើបទ្រង់ឈប់ ។ នៅពេលនោះ. ព្រះអង្គម្ចាស់បាម៉ានបានគង់នៅជិតព្រះអង្គដើម្បីដង្ហែព្រះអង្គ ចំណែកឯព្រះអង្គម្ចាស់ប៉ែរ៉ិស ក៏បរសេះយាងចេញទៅមុខក្បួន ដើម្បីបង្ហាញផ្លូវ ។ លុះយាងទៅដល់ទីមើលទៅឃើញផ្ទះ ព្រះអង្គម្ចាស់ប៉ែរ៉ិសក៏បំផាយសេះយ៉ាងលឿនទៅមុន ដើម្បីទូលព្រះនាងឱ្យដឹងថា ព្រះបាទស៊ុលតង់យាងមកជិតដល់ហើយ ។ ប៉ុន្តែដោយពួកអ្នកបម្រើ ដែលព្រះនាងបានបង្គាប់ឱ្យឈរអមសង្ខាងរុក្ខវិថី បានទូលព្រះនាងមុននេះរួចទៅហើយ. ព្រះអង្គម្ចាស់ក៏បានឃើញព្រះនាងរៀបចំព្រះកាយជាស្រេច បម្រុងចាំទទួលព្រះរាជា ។

- ព្រះបាទស៊ុលតង់ក៏យាងទៅដល់ ចូលកាត់តាមទីធ្លា រួចក៏យាងចុះពីខ្នងសេះនៅត្រង់ទីខាងមុខល្វែងក្រៅនៃផ្ទះ។ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក៏យាងចេញមកអោនថ្វាយបង្គំព្រះអង្គ។ ព្រះអង្គម្ចាស់ព្រះវៀមដែលគង់នៅជិតនោះ ក៏ទូលព្រះបាទស៊ុលតង់ភ្លាមថា នេះគឺ



ព្រះអនុជក្សត្រីរបស់ទ្រង់ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ឱនទាញព្រះហស្តព្រះនាងឱ្យទ្រង់ងើបឡើង។ រួចក្រោយពីព្រះអង្គបានគង់សរសើររូបសម្បត្តិ. ឫកពាចរិយា ព្រមទាំងទឹកព្រះភក្ត្រដ៏ស្រស់ស្រាយរបស់ព្រះនាងអស់ពេលមួយសន្ទុះហើយ. ព្រះអង្គក៏មានព្រះបន្ទូលថា : "បងទាំងពីរសែនដូចប្អូន. ឯប្អូនក៏សែនដូចបងអីម្លេះ ហើយបើតាមខ្ញុំពិចារណាមើលចិត្តគំនិតបងទាំងពីរនេះទៅ. ខ្ញុំយល់ថាបងទាំងពីរនេះពុំដែលហ៊ានសម្រេចធ្វើអ្វីមុនបានសួរយោបល់ប្អូនឡើយ។ ប៉ុន្តែខ្ញុំសង្ឃឹមថា ខ្ញុំនឹងដឹងរឿងនេះច្បាស់ទៅទៀត កាលបើខ្ញុំបានមើលផ្ទះនេះរួចហើយសិន" ។

នៅពេលនោះ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា : "បពិតព្រះករុណាថ្លៃវិសេស គឺជាផ្ទះនៅស្រុកស្រែ ។ ផ្ទះនេះសមតែនឹងឋានៈមនុស្សដូចជាខ្ញុំម្ចាស់នេះ ដែលប្រកបការរស់នៅឆ្ងាយដាច់ពីចំណោមមហាជន ។ ផ្ទះនេះគ្មានកន្លែងត្រង់ណាអាចឱ្យប្រៀបប្រដូចបានទៅនឹងផ្ទះនៅក្នុងទីក្រុងធំៗទេ. ហើយបើប្រៀបទៅនឹងប្រាសាទដ៏ល្អដែលគេសាងទុកថ្វាយតែព្រះមហាក្សត្រទាំងឡាយគង់នោះ. ឃើញថាផ្ទះនេះរឹតតែអន់ថយណាស់ទៅទៀតទៅហើយ" ។

- ខ្ញុំពុំព្រមជឿតាមសម្ដីនាងទាំងអស់បានទេ ព្រះរាជាមានព្រះបន្ទូល? តាមដែលខ្ញុំបានឃើញខ្លះមកហើយនោះៗខ្ញុំហាក់ដូចជាសង្ស័យនឹងសុវាចានាងនេះណាស់ ។ ដូច្នេះ ខ្ញុំនឹងវិនិច្ឆ័យក្នុងចិត្តថា

ដូចម្តេចបាន កាលបើនាងនាំខ្ញុំមើលផ្ទះនេះសិន ។ ដូច្នេះ សូមនាងអញ្ជើញទៅមុខនាំផ្លូវខ្ញុំ ។

ព្រះអង្គម្ចាស់ក្សត្រី ក៏នាំព្រះបាទស៊ុលតង់ទតមើលបន្ទប់ពីមួយទៅមួយគ្រប់ទាំងអស់ លើកលែងតែបន្ទប់ទទួលភ្ញៀវមួយចេញ ។ ព្រះបាទស៊ុលតង់ក្រោយពីបានពិនិត្យមើលបន្ទប់គ្រប់កន្លែងទាំងអស់ នឹងក្រោយពីបានសរសើរនូវភាពផ្សេងៗពីគ្នា ក៏មានព្រះបន្ទូលទៅកាន់ព្រះអង្គម្ចាស់ក្សត្រីថា : "នាងក្រមុំ, នាងឱ្យឈ្មោះផ្ទះនេះថា ជាផ្ទះនៅជនបទឬ? ទីក្រុងយ៉ាងល្អៗ ហើយយ៉ាងធំៗផងនឹងទៅជាកន្លែងគ្មានមនុស្សនៅទៅហើយ បើសិនជាផ្ទះទាំងឡាយនៅស្រុកស្រែល្អដូចជាផ្ទះនាងនេះ ។ ខ្ញុំឥតឆ្ងល់ទៀតឡើយ នាងសប្បាយចិត្តនឹងរស់នៅទីនេះណាស់ ហើយនាងប្រហែលជាស្អប់ខ្ពើមទីក្រុងហើយ ។ សុំនាំខ្ញុំទៅមើលសួនច្បារផង ខ្ញុំសង្ឃឹមថា សួនច្បារនោះនឹងល្អសមគ្នានឹងផ្ទះពុំខាន" ។

ព្រះអង្គម្ចាស់ក្សត្រីក៏បើកទ្វារផ្លូវទៅកាន់សួនច្បារ ហើយរបស់ដែលធ្វើឱ្យព្រះអង្គចាប់ចក្ខុជាងគេ គឺទឹកផុសជាកណ្តាប់ស្រូវ, មានពណ៌លឿងដូចជាមាស ។ ព្រះអង្គក៏ទ្រង់គង់ទតទស្សនីយភាពចម្លែកនេះដោយសេចក្តីងឿងឆ្ងល់នឹងស្ងប់ស្ងែង រួចក៏មានព្រះបន្ទូលថា : "ទឹកអស្ចារ្យគួរឱ្យគយគន់យ៉ាងសប្បាយនេះចេញមកពីណា? តើដើមទឹកនៅឯណា? ហើយដោយវិជ្ជាសិល្ប៍អ្វី បានជាគេអាចធ្វើឱ្យខ្សែទឹក



បាញ់ចេញឡើងដូច្នេះបាន ហើយដែលខ្ញុំយល់ថានៅក្នុងលោកយើងនេះ គ្មានរបស់យ៉ាងនេះមកប្រដូចបានឡើយ? ខ្ញុំចង់មើលរបស់អស្ចារ្យនេះឱ្យបានជិតបំផុត" មានព្រះបន្ទូលដូច្នេះបណ្តើរ, ព្រះអង្គក៏យាងចូលទៅជិតបណ្តើរដែរ ។ បន្ទាប់ពីនោះមក, ព្រះអង្គម្ចាស់ក្សត្រីក៏បាននាំព្រះអង្គទៅទតមើលឈើចេះច្រៀងទៀត ។

លុះយាងទៅដល់ជិតកន្លែងនោះ, ព្រះបាទស៊ុលតង់ទ្រង់ព្រះសណ្តាប់ឮសម្លេងតន្ត្រីយ៉ាងប្លែកខុសពីតន្ត្រី ដែលព្រះអង្គទ្រង់បានព្រះសណ្តាប់មក, ព្រះអង្គក៏ឈប់គង់នៅស្ងៀម ហើយទ្រង់ក៏ខំងាករកមើល តើពួកភ្លេងនៅឯណា ។ លុះព្រះអង្គឥតទតឃើញនរណាម្នាក់ទោះនៅទីជិតក្តីឆ្ងាយក្តី ក៏ប៉ុន្តែព្រះអង្គនៅតែព្រះសណ្តាប់ឮតន្ត្រីផ្សេងៗគ្នា ទើបព្រះអង្គទ្រង់ត្រាស់សួរទៅ ព្រះអង្គម្ចាស់ក្សត្រីបារីសាដថា : "នាងក្រមុំ ចុះពួកអ្នកភ្លេងដែលខ្ញុំឮសូរលេងនេះ នៅឯណា? អ្នកទាំងនោះនៅក្នុងដី ឬអ្នកទាំងនោះបំបាំងខ្លួនក្នុងអាកាសឬ?"

បើតាមសម្លេងលេងដ៏សែនពិរោះគួរឱ្យចាប់ចិត្តនេះ អ្នកភ្លេងទាំងនោះ គួរណាស់តែបង្ហាញខ្លួនឱ្យឃើញផង ព្រោះពួកអ្នកភ្លេងទាំងនោះបានធ្វើឱ្យកើតការសប្បាយ ។

- បពិត្រព្រះករុណាថ្លៃវិសេស, ព្រះអង្គម្ចាស់ក្សត្រីទ្រង់ឆ្លើយតបដោយញញឹមថា, មិនមែនមនុស្សទេដែលបានប្រគុំតន្ត្រីលាន់ឮទ្រហឹងនេះ, គឺជាដើមឈើដែលព្រះអង្គទតឃើញនៅខាងមុខព្រះអង្គ

នេះ. ហើយបើសិនជាព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យយាងចូលទៅមុខចំនួនមួយជំហានទៀត. នោះព្រះអង្គនឹងទ្រង់អស់សង្ស័យ ហើយសម្លេងនឹងឮកាន់តែច្បាស់ឡើង ។

ព្រះបាទស៊ុលតង់ក៏យាងចូលទៅមុខ ហើយព្រះអង្គហាក់ដូចជាត្រូវស្នេហ៍នឹងភ្លេងដ៏ពិរោះនោះ ប៉ុន្តែព្រះអង្គមិនបានបណ្ដែតអារម្មណ៍ឱ្យលង់ទៅតាមសូរភ្លេងនោះទេ ទើបទ្រង់ត្រាស់សួរទៅព្រះអង្គម្ចាស់ក្សត្រីថា : "នាងក្រមុំខ្ញុំសូមអង្វរ. តើដើមឈើគួរស្ញើចនេះដុះឡើងឯង១ក្នុងសួននាងឬ? ឬមួយក៏ជាអំណោយដែលគេបានធ្វើដល់នាងឬក៏នាងបាននាំយកមកពីប្រទេសណាមួយដ៏ឆ្ងាយ? តាមខ្ញុំស្មានដើមឈើ នេះត្រូវស្ថិតនៅទីឆ្ងាយណាស់ បើសិនជាមិនដូច្នេះទេ នោះខ្ញុំប្រាកដជាបានឮគេដំណាលពុំខាន ព្រោះខ្ញុំជាអ្នកចូលចិត្តចង់ឃើញរបស់កម្រ១ ដែលកើតពីធម្មជាតិណាស់ ។ ចុះនាងហៅឈ្មោះដើមឈើនេះដូចម្ដេចទៅ?"

-បពិត្រព្រះករុណាថ្លៃវិសេស. ព្រះនាងមានព្រះសវនីយ៍ ដើមឈើនេះបានទទួលឈ្មោះថា ដើមឈើចេះច្រៀង ហើយដើមឈើនេះឥតដុះនៅក្នុងប្រទេសនេះទេ ។ គេត្រូវការពេលច្រើនណាស់ ដើម្បីនិយាយរៀបរាប់ឱ្យបានសព្វគ្រប់ថា តើដោយរឿងហេតុយ៉ាងណា បានជាដើមឈើនេះបានមកនៅក្នុងទីនេះ ។ គឺជារឿងដែលទាក់ទងទៅនឹងទឹកពណ៌លឿងនឹងបក្សាចេះនិយាយ ព្រោះដើមឈើនេះបានមក



ជាមួយគ្នានឹងវត្ថុពីរមុខនេះដែរ ។ ប៉ុន្តែបើព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យចង់ដឹង. ខ្ញុំម្ចាស់ក៏មានសេចក្ដីរីករាយនឹងនិយាយថ្វាយដែរ បន្ទាប់ពីពេលព្រះអង្គទ្រង់សម្រាក មានព្រះកាយពលស្រួលបួលឡើងវិញ ក្រែងព្រះអង្គទ្រង់នឿយហត់នឹងការប្រមាញ់កណ្ដាលកំដៅព្រះអាទិត្យ ។

- នាងក្រមុំ. ព្រះបាទស៊ុលតង់មានព្រះបន្ទូល ខ្ញុំឥតមាននឿយហត់នឹងស្ដាប់រឿងនាងសោះ ព្រោះរឿងនាងមានផលប្រយោជន៍ច្រើនដល់ខ្ញុំ ។ សូមនាងកុំបារម្ភក្រែងខ្ញុំធុញទ្រាន់អស់កម្លាំង នឹងទ្រាំស្ដាប់រឿងនាងឱ្យសោះ ។ ដូច្នេះ. សូមយើងទៅមើលទឹកពណ៌លឿងឱ្យហើយសិន ហើយខ្ញុំមានសេចក្ដីអន្ទះអន្ទែងពន់ប្រមាណចង់មើលបក្សាចេះនិយាយទៀត ។

កាលបើព្រះបាទស៊ុលតង់ ទ្រង់យាងទៅដល់កន្លែងទឹកពណ៌លឿង. ព្រះអង្គក៏ទ្រង់ខំសម្លឹងមើលខ្សែទឹក ដែលបាញ់ចេញឡើងពីអាងកើតទៅជាកណ្ដាប់ស្រូវ ។ ខ្សែទឹកនេះបាញ់ឡើងខ្ពស់ ហើយធ្លាក់ចុះមកក្នុងអាងវិញគ្មានឈប់ឈរសោះ ។ ព្រះអង្គអត់ទ្រាំពុំបានក៏មានព្រះបន្ទូលសួរទៅព្រះអង្គម្ចាស់ក្សត្រីថា : "បើតាមនាងពោលទឹកនេះគ្មានប្រភពទេ. ហើយទឹកនេះគ្មានបំពង់បង្ហូរមកពីទីជិតខាង ឬក៏មកពីក្រោមដីនេះទេ ។ តែខ្ញុំអាចយល់បានខ្លះថា ទឹកនេះជារបស់ចម្លែកអស្ចារ្យ ដូចជាដើមឈើចេះច្រៀងដែរ" ។

- បពិត្រព្រះនរបតី, ព្រះអង្គម្ចាស់ក្សត្រីមានសវនីយ៍ រឿងនេះដូចជាព្រះអង្គមានព្រះបន្ទូលមែន ។ ហើយជាភស្តុតាងពិតប្រាកដថា ទឹកនេះឥតហូរមកពីណាទេនោះ គឺដោយអាងនេះមានតែមួយបន្ទប់ប៉ុណ្ណោះ ។ ដូច្នេះទឹកក៏មិនអាចហូរចូលពីខាង ឬពីក្រោមបានឡើយ ។ ឯការដែលទឹកនេះកើតទៅជារបស់អស្ចារ្យ ដល់ចក្ខុព្រះអង្គនោះ គឺបណ្ដាលមកពីទឹកមួយដបតូច ដែលខ្ញុំម្ចាស់បានចាក់ទៅក្នុងអាង រួចទឹកមួយដបនោះក៏រីកទំហំឡើងពេញអាង ដោយគុណធម៌ពិសេសរបស់វា ដូចដែលព្រះអង្គទ្រង់ទតឃើញស្រាប់នេះ" ។ តមក, ព្រះបាទស៊ុលតង់ក៏យាងថយចេញឆ្ងាយពីអាងទឹក ព្រមទាំងមានព្រះបន្ទូលថា: "ចំពោះការទស្សនារបស់ខ្ញុំលើកដំបូងនេះ ប៉ុណ្ណេះឃើញថាល្មមគ្រប់គ្រាន់ហើយ ព្រោះខ្ញុំសន្យាក្នុងចិត្តថា នឹងមកមើលកន្លែងនេះឱ្យបានញឹកញយ ។ ឥឡូវសូមនាំខ្ញុំទៅមើលបក្សាចេះនិយាយទៀត" ។

បន្ទាប់ពីនោះមក, ព្រះបាទស៊ុលតង់ក៏យាងត្រឡប់ទៅកាន់លំនៅព្រះអង្គម្ចាស់ក្សត្រីវិញ ។ លុះព្រះអង្គយាងចូលទៅជិតបន្ទប់ទទួលភ្ញៀវ ព្រះអង្គក៏ទតឃើញបក្សាបក្សីជាច្រើនរាប់ពុំអស់ ទំនៅលើដើមរុក្ខាលតាវល្លិ៍នានាកំពុងស្រែកយំរៀង១ខ្លួន លាន់សូរកកែកករទ្រហឹងអឺងកង ។ ព្រះរាជាក៏ទ្រង់ត្រាស់សួរថា ចុះហេតុអ្វីបានជាបក្សាទាំងនេះ បានបបួលគ្នាមកទំកុះករនៅទីនេះ ម្ដេចមិនទៅទំដើមឈើឯទៀតក្នុងសួន ព្រោះនៅទីនោះព្រះអង្គពុំដែលឃើញ ឬឮសត្វអ្វីយំ



សោះឡើយ ។ ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់ឆ្លើយទូលថា បក្សាទាំងឡាយបានហើរមកពីទីជិតខាងនេះ ដើម្បីយំបន្ទរតាមសម្លេងបក្សាចេះនិយាយ ។ ព្រះករុណានឹងអាចទតឃើញបក្សាចេះនិយាយនោះ នៅក្នុងទ្រុងដាក់លើមាត់បង្អួចបន្ទប់ ដែលព្រះអង្គនឹងយាងចូលទៅនេះ ។ ហើយបើសិនជាព្រះអង្គទ្រង់យកព្រះទ័យផ្ទៀងស្ដាប់បន្តិច, នោះព្រះអង្គនឹងបានជ្រាបថា បក្សានេះមានសម្លេងឮជាងសម្លេងបក្សាឯទៀតទាំងអស់, សូម្បីតែសត្វចាបម្យ៉ាងដែលល្បីឈ្មោះខាងយំនោះ ក៏ពុំអាចយំឮជាងបក្សានេះដែរ ។

ព្រះបាទស៊ុលតង់ក៏បានយាងចូលទៅដល់ក្នុងបន្ទប់ទទួលភ្ញៀវ ។ ហើយដោយបក្សាកំពុងតែស្រែកយំ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ទៅកាន់បក្សាថា : "បក្សា, នេះជាព្រះបាទស៊ុលតង់, ចូរអ្នកសម្ដែងអភិវន្ទនាការចំពោះព្រះអង្គ" ។ បក្សាចេះនិយាយព្រមទាំងបក្សាឯទៀតក៏ឈប់យំមួយរំពេច ហើយបក្សាអស្ចារ្យក៏និយាយថា : "សូមឱ្យព្រះបាទស៊ុលតង់បានប្រកបតែដោយសេចក្ដីរីករាយ សូមឱ្យព្រះអាទិទេពជួយចម្រុងចម្រើនព្រះអង្គ ឱ្យប្រកបតែនឹងភាពរុងរឿង-ថ្កុំថ្កើង, និងសូមឱ្យព្រះអាទិទេពជួយបង្កើនព្រះជន្មព្រះអង្គឱ្យបានវែងឆ្ងាយតទៅទៀត" ។

ដោយម្ហូបម្ហាក្រយាព្រះស្ងោយបានរៀបចំតម្កល់ទុកជាស្រេចនៅលើកៅអីទំរេត ក្បែរបង្អួចដែលគេដាក់ទ្រុងបក្សានោះ ព្រះអង្គក៏

ទ្រង់គង់សោយក្រយាព្រះស្ងោយ ដោយមានព្រះបន្ទូលថា : “បក្សា, យើងអរគុណនឹងសេចក្ដីគួរសមរបស់ឯងណាស់ ហើយយើងសប្បាយចិត្តនឹងបានឃើញឯងដូចជាព្រះបាទស៊ុលតង់ និងជាស្ដេចនៃបក្សាទាំងអស់” ។

ព្រះបាទស៊ុលតង់ កាលបើទ្រង់ទតឃើញម្ហូបត្រសក់នៅមុខព្រះអង្គ ហើយដែលព្រះអង្គយល់ថាជាត្រសក់ញាត់ទឹមធម្មតា ក៏ទ្រង់លូកព្រះហស្តទៅចាប់សោយ ប៉ុន្តែព្រះអង្គស្រាប់តែកើតសេចក្ដីងឿងឆ្ងល់ជាក្រៃលែង ដោយទតឃើញទឹមនោះធ្វើអំពីគជ់ទៅវិញ, ទើបព្រះអង្គមានព្រះបន្ទូលថា : “ចុះអ្វីក៏ប្លែកម្ល៉េះ ! គេនឹកឃើញយ៉ាងណាបានជាគេធ្វើទឹមអំពីគជ់ដូច្នេះ? គជ់គេឥតបរិភោគទេ” ។ ព្រះអង្គក៏ទ្រង់សម្លឹងមើលទៅព្រះអង្គម្ចាស់ទាំងពីរ និងព្រះអង្គម្ចាស់ក្សត្រីដើម្បីចង់ដឹងថា តើរបស់នោះមានន័យដូចម្ដេច, ប៉ុន្តែបក្សាក៏បានឆ្លើយជូសព្រះអង្គម្ចាស់ទាំងឡាយថា : “បពិត្រព្រះរាជាដ៏ចម្រើន, ព្រះអង្គទ្រង់ចេះកើតសេចក្ដីងឿងឆ្ងល់ជាពន្លឹកភ្លាម នឹងទឹមធ្វើអំពីគជ់ដែលព្រះអង្គទ្រង់ទតឃើញផ្ទាល់នឹងចក្ខុព្រះអង្គនេះ, ចុះហេតុអ្វីក៏ព្រះអង្គមិនទ្រង់ងឿងឆ្ងល់ភ្លាមផង ម្ដេចក៏ទ្រង់ឆាប់ជឿគេអ្វីម្ល៉េះអំពីការដែលស្រីឆ្មបក្រាបទូលថា ព្រះនាងស៊ុលតានប្រសូតបុត្រមកជាសត្វឆ្កែ, សត្វឆ្មា នឹងជាដុំឈើនោះ?

- បានជាខ្ញុំជឿ, ព្រះបាទស៊ុលតង់មានព្រះឱង្ការ, ព្រោះស្រីឆ្មបបានប្រាប់ខ្ញុំ ។



- ព្រះករុណាទ្រង់ជ្រាបទេថា, បក្សាពោល, ស្រីឆ្មបទាំងនោះជាបងស្រីបង្កើតរបស់ព្រះនាងស៊ុលតាន ប៉ុន្តែជាបងស្រីអាក្រក់ក្រៃលែងមានចិត្តច្រណែនឫស្យាឈ្នានិះតែនឹងប្អូនឯង ដោយឃើញព្រះអង្គទ្រង់សព្វព្រះទ័យស្រឡាញ់ព្រះនាងយកធ្វើជាមហេសី មិនឯស្រឡាញ់វាឯណោះវិញ ។ ហើយដើម្បីបំពេញការចងគំនុំរបស់វា, វាបាននាំគ្នាពោលបំភ័ន្តព្រះអង្គ ។ ស្រីទាំងនោះនឹងឆ្លើយទទួលសារភាពខ្លួនពុំខាន, បើសិនជាព្រះអង្គហៅវាមកសួរចម្លើយ ។ បងប្អូនប្រុសពីរនាក់និងនាងស្រីជាប្អូននេះ គឺជាព្រះរាជបុត្រាបុត្រីព្រះអង្គហើយ ដែលត្រូវស្រីឆ្មបដាក់ក្នុងកញ្ច្រែងបណ្ដែតបំបរបង់ចោលតាមប្រឡាយទឹក ប៉ុន្តែដោយហេតុតែកុសលផលបុណ្យលោកជួយ, ព្រះអង្គម្ចាស់នឹងព្រះអង្គម្ចាស់ក្សត្រីក៏ត្រូវសពលោកនាយតម្រួតសួន រើសយកមកចិញ្ចឹមបីបមថ្នមថ្នាក់ហាក់ដូចជាបុត្រចេញមកពីឈាមលោកបង្កើត ។

សម្ដីរបស់បក្សានេះជាសម្ភារៈមួយយ៉ាងចំណាន ជួយបំភ្លឺការវិនិច្ឆ័យរបស់ព្រះបាទស៊ុលតង់ឱ្យកាន់តែច្បាស់ឡើងមួយរំពេច ទើបព្រះអង្គទ្រង់លាន់ព្រះឱស្ឋយ៉ាងខ្លាំងថា : “បក្សា, យើងឥតមានអល់ឯកក្នុងចិត្តនិងព្រមជឿតាមការពិត ដែលឯងបានពោលបំផុសឡើងនិងបានប្រាប់យើងឱ្យដឹងនេះទេ ។ អំពើទន់ភ្លន់និងពាក្យផ្អែមល្ហែមរបស់យុវជន ដែលធ្វើឱ្យយើងមានសេចក្ដីស្នេហាមកជាច្រើនណាស់ហើយនោះ, បានប្រាប់យើងច្បាស់ណាស់ទៅហើយថា យុវជនយុវតីទាំងនេះប្រាកដជាញាតិសារលោហិតរបស់យើង ។ ដូច្នេះបុត្រាបុត្រី

ទាំងឡាយ ចូរឯងចូលមកជិតបិតា. បិតានឹងឱបរឹតឯង ដើម្បីសម្តែងសញ្ញានៃសេចក្តីស្នេហារបស់បិតាជាលើកដំបូងបំផុត ចំពោះឯងរាល់គ្នា" ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ងើបឈរឡើង ចូលទៅចាប់ត្រកងឱបរឹតព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីជាបន្តបន្ទាប់គ្នា ហើយក៏ទ្រង់ព្រះកន្សែងជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងនោះយ៉ាងយូរ ។ បន្ទាប់មកព្រះអង្គក៏មានព្រះបន្ទូលថា : "ប៉ុណ្ណេះមិនទាន់គ្រប់គ្រាន់ទេ កូនប្រុសកូនស្រីបិតាអើយ ! សូមកូនទាំងឡាយឱបរឹតគ្នាទាំងបីនាក់ឡើង ក្នុងឋានៈជាកូនបិតា កើតចេញមកពីព្រះលោហិតស្តេចប្រទេសពែរ្ស៊ី. ដែលមានឯងរាល់គ្នានេះហើយ ត្រូវរក្សាកិត្តិគុណរបស់ប្រទេស. មិនមែនឱបរឹតគ្នា ក្នុងឋានៈជាបុត្រលោកនាយតម្រួតសួនទេ ដែលបិតាត្រូវតែដឹងគុណលោកឥតភ្លេចសោះឡើយ ព្រោះលោកបានជួយស្រោចស្រង់អ្នក. ឱ្យមានជីវិតរស់ឡើងជាមនុស្សនឹងគេ ម្ល៉េះសមបិតាខានបានឃើញមុខកូនឯង ហើយកូនឯងក៏ខានបានឃើញព្រះភក្ត្របិតាដែរ" ។

បន្ទាប់ពីព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីបានឱបរឹតគ្នាដោយសេចក្តីស្នេហាជាទីបំផុត និងដោយសេចក្តីសប្បាយមួយថ្មីតាមបំណងព្រះបាទស៊ុលតង់ហើយ. ព្រះបាទស៊ុលតង់ក៏ទ្រង់ចាប់សោយក្រយាព្រះស្ងោយជាមួយនឹងបុត្រាបុត្រីព្រះអង្គដោយសេចក្តីរីករាយរកអ្វីប្រៀបគ្មាន ។ ប៉ុន្តែ ព្រះអង្គទ្រង់សោយយ៉ាងប្រញិបប្រញាប់ជាទីបំផុត ។ លុះសោយហើយភ្លាម ទ្រង់ក៏មានព្រះបន្ទូលថា : "កូនទាំង



ឡាយ. ឯងរាល់គ្នាបានស្គាល់រូបបិតាហើយ ស្អែកនេះបិតានឹងនាំមាតាឯងមកឱ្យឯងស្គាល់ទៀត សូមកូនរៀបចំខ្លួនចាំទទួលមាតាឯងចុះ" ។

ព្រះបាទស៊ុលតង់ក៏យាងឡើងគង់លើសេះត្រឡប់ទៅរាជធានីវិញយ៉ាងលឿងក្រៃលែង ។ លុះព្រះអង្គយាងទៅដល់មហាប្រាសាទភ្លាម. ការដែលព្រះអង្គត្រូវធ្វើជាដំបូងបង្អស់ គឺទ្រង់ត្រាស់បង្គាប់ទៅលោកនាយករដ្ឋមន្ត្រីឱ្យទៅកោះហៅបងស្រីព្រះនាងស៊ុលតានទាំងពីរនាក់ ឱ្យចូលមកគាល់ព្រះអង្គជាប្រញាប់ ។ គេក៏បានទៅចាប់នាំខ្លួនស្រីពីរនាក់នោះមកសួរចម្លើយម្នាក់ម្តង១ ឃើញថាបានប្រព្រឹត្តអំពើលាមកមែន. ហើយក៏ផ្តន្ទាទោសតាមកំហុស ដោយត្រូវយកដៃជើងទាំងបួនទៅចងជាប់នឹងសត្វសេះបួនដែរ ហើយវាយសេះនោះឱ្យបោលទៅទីផ្សេងគ្នា. ប្រទាញប្រទង់ខ្លួនមនុស្សទោសលុះត្រាដាច់ជាបួនកំណាត់ ។

នៅពេលនោះ ព្រះបាទស៊ុលតង់កូរូសា ដោយមានព្រះរាជបរិពារក្នុងព្រះបរមរាជវាំងហែហមផង ក៏យាងផ្ទាល់ព្រះបាទលុះត្រាទៅដល់មាត់ទ្វារនៃព្រះវិហារអ៊ីស្លាមដែលធំជាងគេ ។ រួច. បន្ទាប់ពីព្រះអង្គបានយាងចូលទៅផ្ទាល់ព្រះអង្គនាំព្រះនាងស៊ុលតានពីទីគុកដ៏តូច ដែលជាកន្លែងដែលព្រះនាងបានត្រូវគេដាក់ឃុំឃាំងឱ្យនៅសង្រោកសង្រេង សោយទុក្ខសោយទោសពន់ប្រមាណជាច្រើនឆ្នាំមកហើយ ។ ចេញផុតមកខាងក្រៅហើយ. ព្រះអង្គក៏ឱបរឹតព្រះនាង ហើយទ្រង់ព្រះកន្សែងរអាក់រអួលប្រកបដោយទឹកព្រះនេត្រាហូរចេញមកយ៉ាង

សស្រាក់ឥតឈប់ឈរ ដោយព្រះអង្គទតឃើញព្រះនាងមានភាពគួរឱ្យអាណិតអាសូរជាពន់ពេកណាស់, ទើបព្រះអង្គខំប្រឹងមានព្រះបន្ទូលដូច្នេះថា : "ម្ចាស់អូន, ខ្ញុំមកនេះ ដើម្បីសូមទោសម្ចាស់អូន ចំពោះអំពើអយុត្តិធម៌ដែលខ្ញុំបានប្រព្រឹត្តដោយអចេតនាទៅលើរូបអូន, ហើយនិងដើម្បីសូមជួសជុលជំងឺចិត្តអូន ការណ៍នេះខ្ញុំបានធ្វើរួចខ្លះទៅហើយ គឺខ្ញុំបានផ្ដន្ទាទោសអ្នកដែលបាននាំខ្ញុំឱ្យធ្វើខុស ដោយកិច្ចបោកបញ្ឆោតខ្ញុំយ៉ាងអប្រិយ៍ ហើយខ្ញុំសង្ឃឹមថាម្ចាស់អូននឹងយល់ថា ការជួសជុលផ្លូវចិត្តនោះល្មមគ្រប់គ្រាន់ណាស់ហើយ កាលបើខ្ញុំនឹងធ្វើអំណោយព្រះអង្គម្ចាស់ពីរព្រះអង្គយ៉ាងប្រសើរ, និងព្រះអង្គម្ចាស់ក្សត្រីមួយព្រះអង្គជាទីស្នេហានេះ ព្រោះព្រះអង្គម្ចាស់, ព្រះអង្គម្ចាស់ក្សត្រីទាំងនេះ គឺជាបុត្រាបុត្រីម្ចាស់អូនឯង នឹងជាបុត្រាបុត្រីយើងទាំងអស់គ្នា។ ដូច្នេះ សូមយាងម្ចាស់អូន, ហើយសូមម្ចាស់អូនទទួលថានៈព្រមទាំងកិត្តិយសទាំងឡាយ ដែលម្ចាស់អុនត្រូវមានដូចពីដើមវិញ" ។

ការសុំទោសនេះ បានធ្វើឡើងនៅចំពោះមុខប្រជាជនជាច្រើនអនេក ដែលបានរត់ទាំងហ្វូងៗមកពីគ្រប់ទិស នៅពេលដែលបានឮពីដំណឹងនេះភ្លាម ។ ដំណឹងនេះបានផ្សាយពាសពេញទីក្រុងក្នុងពេលដ៏ឆាប់បំផុត ។

ស្អែកឡើង នៅពេលពីព្រលឹមធំ, ព្រះបាទស៊ុលតង់នឹងព្រះនាងស៊ុលតាន, ដោយមានព្រះរាជបរិពារជាច្រើនហែហមផង, ក៏ទ្រង់យាងធ្វើដំណើរទៅកាន់គេហស្ថានព្រះអង្គម្ចាស់នឹងព្រះអង្គម្ចាស់ក្សត្រី។



លុះយាងទៅដល់ បន្ទាប់ពីទ្រង់យាងចុះពីរាជអាជានេយ្យមក ព្រះបាទស៊ុលតង់ ក៏ទ្រង់បង្ហាញព្រះនាងស៊ុលតាន ឱ្យព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ែវិស នឹងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដបានស្គាល់, រួចព្រះអង្គក៏មានព្រះបន្ទូលថា : "ម្ចាស់អូន, ព្រះអង្គម្ចាស់ទាំងពីរនេះជាព្រះរាជបុត្រាអូន, ឯព្រះអង្គម្ចាស់ក្សត្រីនេះជាព្រះរាជបុត្រី ។ សូមម្ចាស់អូនឱបរឹតបុត្រាបុត្រីយើងដូចជាខ្ញុំបានឱបរឹតរួចមកហើយដែរ ។ ព្រះអង្គម្ចាស់ព្រះអង្គម្ចាស់ក្សត្រីទាំងបីព្រះអង្គនេះ សមជាបុត្រាបុត្រីយើងណាស់" ។ នៅក្នុងការឱបរឹតដ៏រំភើបចិត្តនោះ ព្រះជលនេត្របានហូរចេញមកជាច្រើនបំផុត ពិសេសគឺព្រះនាងស៊ុលតាន ព្រោះជាធម្មតារបស់មាតា ដែលបានបែកមុខបុត្រធីតាអស់ពេលជាច្រើនឆ្នាំដោយក្រៀមក្រំ ហើយដែលគ្មានសង្ឃឹមថានឹងបានជួបវិញផង ហើយស្រាប់តែបានជួបមុខកូនកម្សត់វិញយ៉ាងនេះ ។

ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ, និងព្រះអង្គម្ចាស់ក្សត្រីបានខំខ្នះខ្នែងរៀបចំអាហារភោជន ថ្វាយព្រះបាទស៊ុលតង់ និងព្រះនាងស៊ុលតានសោយ ព្រមទាំងមន្ត្រីអ្នករាជការទាំងអស់ ដែលបានហែហមព្រះអង្គទៅបរិភោគទាំងអស់គ្នា ។ លុះក្រោយពេលបាយរួចមក, ព្រះបាទស៊ុលតង់ក៏នាំព្រះនាងស៊ុលតានទៅក្នុងសួនច្បារ, បង្ហាញព្រះនាងឱ្យទតដើមឈើចេះច្រៀង, ទឹកពណ៌លឿង ។ ចំណែកឯបក្សាព្រះនាងបានទតនៅក្នុងទ្រុងហើយៗព្រះអង្គក៏ពោលសរសើរប្រាប់ព្រះនាងសព្វគ្រប់អំពីរឿងបក្សានោះ នៅពេលកំពុងសោយក្រយាព្រះស្ងោយ លុះ

អស់មានការអ្វីដែលត្រូវការឱ្យព្រះអង្គគង់នៅទីនោះតទៅទៀតហើយ ព្រះអង្គក៏ទ្រង់ឡើងគង់ព្រះរាជអាជានេយ្យ ធ្វើព្រះរាជដំណើរចេញទៅព្រះបរមរាជវាំងវិញ។ ព្រះអង្គម្ចាស់បាម៉ានគង់សេះនៅពីខាងស្តាំព្រះអង្គ, ព្រះអង្គម្ចាស់ប៉ែរិសពីខាងឆ្វេង ព្រះនាងស៊ុលតាននឹងព្រះអង្គម្ចាស់ក្សត្រីពីខាងដែរ តែយាងពីក្រោយព្រះបាទស៊ុលតង់, បន្ទាប់មកទើបពួកមន្ត្រីក្នុងព្រះបរមរាជវាំងអញ្ជើញបន្តបន្ទាប់គ្នាតាមថានៈយសសក្តិ។ លុះក្បួនដង្ហែបានទៅដល់ជិតទីក្រុង ពួកប្រជាជនដែលបានទៅដល់មុនក៏រត់ចេញពីផ្ទះមកប្រសាចឈរចាំមើលក្បួន ។ អ្នកទាំងនោះបានខំសម្លឹងមើលព្រះនាងស៊ុលតាន និងព្រះអង្គម្ចាស់ទាំងពីរព្រមទាំងព្រះអង្គម្ចាស់ក្សត្រីច្រើនជាងគេបំផុត ដោយមានការស្រែកទះដៃអបអរសាទផង ព្រោះគេសប្បាយនឹងបានឃើញព្រះនាងស៊ុលតាន បានរួចអំពីអំពើទារុណកម្មយ៉ាងវេទនា ។ ក្រៅពីនេះ, ប្រជាជនបានខំសម្លឹងមើលបក្សាក្នុងទ្រុង ដែលព្រះនាងប៉ារីសាដបានដាក់នៅមុខព្រះនាង ។ អ្នកទាំងនោះបានសរសើរដល់សម្រែកបក្សា ដែលចេះហៅបក្សាឯទៀតឱ្យហើរតាម ដោយទំលើដើមឈើនានាក្នុងស្រុកស្រែ និងនៅលើដំបូលផ្ទះតាមវិថីនៃរាជធានី ។

នៅទីបំផុត ព្រះអង្គម្ចាស់បាម៉ាន, ប៉ែរិសនិងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដក៏បានយាងទៅដល់ព្រះបរមរាជវាំង ដោយសេចក្តីរុងរឿងជាទីបំផុត ។ ហើយនៅល្ងាចនោះ គេបានរៀបចំអុជប្រទីបផ្កាលាភ្លឺព្រោងព្រាតដូចជាថ្ងៃ ព្រមទាំងមានលេងល្បែងកំសាន្តផ្សេងៗទាំង



នៅខាងក្នុងព្រះរាជវាំង និងនៅក្នុងទីក្រុងទាំងមូល ។ ពិធីនេះបានបន្តទៅជាយូរថ្ងៃទើបឈប់ ។

កាលបើទ្រង់ព្រះសណ្តាប់រឿងមកដល់ត្រង់កន្លែងនេះ ព្រះចៅស៊ុលតង់ប្រទេសឥណ្ឌា ក៏ទ្រង់អត់ទ្រាំពុំសរសើរបញ្ញាដ៏ខ្ពង់ខ្ពស់របស់ព្រះនាងស៊ុលតាន ជាមហេសីព្រះអង្គពុំបាន ដែលចេះរករឿងយ៉ាងប្លែកៗពិរោះៗនិយាយថ្វាយព្រះអង្គទ្រង់ព្រះសណ្តាប់កំសាន្តជារាល់រាត្រីឥតដែលខានសោះឡើយ ។

រឿងមួយពាន់មួយយប់ក៏សន្មតថា ចប់សព្វគ្រប់នៅកណ្តាលការសប្បាយទាំងនោះ។ គឺរឿងមួយពាន់មួយយប់នេះឯងហើយ ដែលបានជួយបន្ថយការប្រមាណខុសរបស់ព្រះបាទស៊ុលតង់ទៅលើភក្តីភាពនៃស្ត្រីទាំងអស់ ។ ព្រះអង្គក៏ទ្រង់បានត្រជាក់ព្រះទ័យឡើងវិញ ហើយព្រះអង្គទ្រង់ជឿជាក់ដល់គុណូបការៈ និងគតិបណ្ឌិតដ៏ទូលំទូលាយរបស់ព្រះនាងសេហេរ៉ាសាដ ។ ព្រះអង្គទ្រង់ព្រះចិន្តាឃើញដល់សេចក្តីក្លាហានរបស់ព្រះនាង ដែលព្រះនាងបានសុំខ្លួនដោយស្ម័គ្រចិត្តមកធ្វើជាមហេសីព្រះអង្គ គ្មានខ្លាចស្លាប់សោះ ព្រោះព្រះនាងក៏ដឹងខ្លួនឯងថាព្រះនាងនឹងត្រូវគេយកទៅសម្លាប់ចោលនៅថ្ងៃស្អែកបន្ទាប់ពីយប់ដែលនាងត្រូវមកនៅរួមរក្សស្នេហ៍ស្ម័គ្រមេត្រីជាមួយព្រះអង្គ, ដូចជានារីមុនៗឯទៀតដែរ ។

ការពិចារណាឱ្យឃើញដូច្នេះ រួមជាមួយនឹងគុណសម្បត្តិដ៏ល្អជាច្រើនដែលព្រះអង្គទ្រង់ធ្លាប់មានមក ក៏បានញ៉ាំងព្រះទ័យព្រះអង្គថា

ត្រូវតែលើកលែងទោសព្រះនាង ទើបព្រះអង្គមានព្រះបន្ទូលថា : “សេ-ហេរ៉ាសាដជាទីស្នេហា, ខ្ញុំយល់ច្បាស់ហើយថា នាងមិនខ្វះរឿងនិយាយប្រាប់ខ្ញុំទេ, ប៉ុន្តែអស់ពេលជាយូរដែរណាស់មកហើយ ដែលនាងបានធ្វើឱ្យខ្ញុំសប្បាយចិត្ត គឺនាងជួយសម្រាលកំហឹងខ្ញុំ ។ ដូច្នេះ, ខ្ញុំសូមបោះបង់ចោលដោយរីករាយ ដើម្បីជាការអនុគ្រោះដល់នាងនូវច្បាប់ដ៏ឃោរឃៅឥតមេត្តា ដែលខ្ញុំបានបង្កើតដោយខ្លួនឯង ។ ដូច្នេះខ្ញុំសូមលើកលែងទោសនាងពីត្រឹមពេលនេះ ហើយសូមនាងសម្គាល់ក្នុងចិត្តថា គឺនាងនេះហើយដែលជាអ្នកជួយដោះទុក្ខនារីទាំងអស់ ដែលត្រូវគេសម្លាប់ចោលតាមគំនុំរបស់ខ្ញុំ” ។ ព្រះនាងសេហេរ៉ាសាដក៏ស្ទុះទៅឱបព្រះបាទព្រះអង្គ, សម្តែងអំណរគុណដ៏ជ្រាលជ្រៅក្រៃលែងចំពោះព្រះអង្គ ។ លោកនាយករដ្ឋមន្ត្រីបានទទួលដំណឹងល្អនេះមុនគេ ផ្ទាល់ពីព្រះឱស្ឋព្រះបាទស៊ុលតង់ហើយមិនយូរប៉ុន្មានដំណឹងលើកលែងទោសនេះ ក៏បានផ្សាយពាសពេញទីក្រុងនិងអាណាខេត្ត ។ ប្រជាជនទាំងអស់នៅក្នុងព្រះរាជាណាចក្រឥណ្ឌាបានប្រសិទ្ធពរថ្វាយព្រះបាទស៊ុលតង់ជាច្រើន និងជាពិសេសពោលសរសើរនឹកដល់គុណព្រះនាងសេហេរ៉ាសាដជាច្រើនអនេកក្រៃលែងរកអ្វីប្រៀបគ្មានឡើយ ។

## រឿងមួយពាន់មួយយប់
## បានបញ្ចប់ដោយបរិបូណ៌